# ច្បាប់ប្រុស



និពន្ធដោយ បណ្ឌិត ម៉ឺន មៃ ជាបទព្រហ្មគីតិ

# ច្បាប់ប្រុស

១. នេះបទព្រហ្មគីតិ ពីព្រេងព្រឹទ្ធទុកទូន្មាន
ចែងចងជានិទាន ទុកគ្រាន់មើលជាច្បាប់ថ្លៃ ។
ឲ្យអស់កូនចៅក្រោយ ស្តាប់កុំឲ្យភ្លេចស្មារតី
ប្រដៅទាំងប្រុសស្រី យកទុកខ្លួនគ្រប់អាត្មា ។
ធម្មតាកើតជាមនុស្ស ទោះស្រីប្រុសក្រណាស់ណា
ក្រគិតក្នុងចិន្តា ឲ្យបានដឹងសមនិងគួរ ។
នឹងអស់ញាតិសន្តាន សោះគេមានពាក្យថាជួ
កុំឆ្មើងកុំតែងតួ ធ្វើកុំប៉ោងកុំពាក្យធំ ។
៥. នឹងដើរដូចភុជង្គ ឲ្យអោនអង្គអាចបារម្ភ
ឲ្យត្រូវនឹងច្បាប់ក្រម គួរប្រតិបត្តិកុំឲ្យឆ្គង ។
រៀនបទរៀនបាទចាស កុំក្រឡាសលើរៀមច្បង
ស្រដីនឹងអ្នកផង ពាក្យឲ្យគួរកុំឯងវើយ ។
អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឲ្យអប្រិយ(អប្បិយ) ស្រដីថាកូនអត់ពូជ ។
ចាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច
គេថាកូនតពូជ មិនគោរពដល់ចាស់ទុំ ។
គេដៀលដល់ម៉ែឪ កេរ្តិ៍អាស្រូវស្អុយរហ៊ឹម
គេស្តីដើមដៀវជុំ ដំនៀលនោះដល់មកចាស់ ។
១០. កុំកាចកុំស្លូតពេក កុំចំអៀករៀនរហ័ស
កុំខ្លាចកុំហ៊ានណាស់ ឲ្យរំពឹងរំពៃគ្រប់ ។
ទោះដេកឲ្យរហ័ស ភ្ញាក់មុនចាស់ដោះឡើងលុប
មុខមាត់មើលឲ្យគ្រប់ ទ្រព្យរបស់សឹមដេកវិញ ។
ស្លាម្លូស៊ីឲ្យច្រៀក កុំបីបៀកទាំងម្លូលមិញ
តូចធំឲ្យច្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ ។
ដេកយប់កុំដេកយូរ ហើយទទូរដូចគេងាប់

# ច្បាប់ប្រុស

សំពត់ស្លៀកឲ្យខ្ជាប់ កុំអាក្រាតនៅក្រៅខ្លួន ។
នឹងដេកកុំទ្រមក់ ឲ្យលង់លក់ក្រៅពីក្បួន
បើភ្ញាក់ឲ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្លាំង ។
១៥. ប្រែប្រាណប្រុងវិញ្ញាណ ខ្លាចក្រែងមានចោរចិត្តខ្មាំង
ប្រួញប្រាណប្រឹបជញ្ជាំង ជញ្ជូនទ្រព្យលួចយកចេញ ។
បើឥតមោះមន្ទិល កុំឲ្យខ្ជិលដេកទៅវិញ
ភ្ញាក់ហើយឲ្យក្រោកចេញ រកជក់ថ្នាំស៊ីម្លូស្លា ។
ទោះពេលពន់ព្រលប់ គន់ឲ្យគ្រប់ទ្រព្យនានា
កាំបិតខាងអាត្មា ឲ្យសិតទឹកដាក់ចុងជើង ។
ប្រដាប់ដាក់ទឹមស្នា ថ្វាយទេព្តារក្សាយើង
ហើយឲ្យបំពាក់ភ្លើង នៅក្រានក្រៅកុំឲ្យដាច់ ។
កុំឲ្យអស់រលីង រលត់ធេងហើយថាភ្លេច
សព្វថ្ងៃមើលកុំដាច់ កុំដើរយកពីផ្ទះគេ ។
២០. ថៃទាំមើលជើងក្រាន ឲ្យអុសមានកុំទំនេរ
បង្កាត់បង្កើតកេរ្តិ៍ កុំប្រហែសឲ្យស្ងន្សស៊ុង ។
ប្រយ័ត្នក្រែងក្រងាយ ពុំសប្បាយឈឺពោះពុង
បង្កាត់កំដៅអង្គ អុជបំភ្លឺមើលនេះនោះ ។
មានកាលយប់ងងឹត ភ្លេចមិនគិតជូនកូនជុះ
គ្មានភ្លើងអុជចន្លុះ ក្រានរលុះរលត់ធេង ។
រត់រកភ្លើងសស្រាក់ ព្រួយលំបាកតែខ្លួនឯង
ហេតុខ្ជិលពុំគិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ ។
ហើយឲ្យថៃទាំងទឹក ទោះយប់ព្រឹកកុំគិតងាយ
ដងដាក់ក្អមរាត់រាយ សព្វបាតពាងអាងអុងធំ ។
២៥. កុំឲ្យស្ងួតក្អមធេង អស់រលីងពីពាងធំ
គ្មានសោះនោះមិនសម ជូនក្រែងក្រងាយយប់ថ្ងៃ ។

# ច្បាប់ប្រុស

ទោះដើរទៅឆ្ងាយជិត　　កាន់កាំបិតកំដរដៃ
ក្រែងមានមែកឈើព្រៃ　　កាប់កាន់មកធ្វើជាអុស ។
ជូនកាលក្រែងបន្លា　　មុតអាត្មាគ្រាន់ចាក់ជួស
ជាគ្រឿងគ្រប់មិនខុស　　ការសត្រូវទោះឆ្មាឆ្កែ ។
ដើរព្រៃឲ្យមើលលើ　　ឃើញស្លឹកឈើជាបន្លែ
កាប់កាន់កុំដៃទទេ　　អង្គុយគន់មើលឆ្វេងស្តាំ ។
ក្រែងមានឈើព្រៃងាប់　　គួរកាច់កាប់យកជាថ្នាំ
ផ្ញើក្រានគ្រាន់ដណ្តាំ　　បាយបានឆ្អិនឆាប់ដូចចិត្ត ។
៣០. សោះស្រីស្រដីបាន　　បើអុសមានមិនព្រួយគិត
សព្វថ្ងៃប្រុងគំនិត　　ថៃទាំទើបគង់របស់ ។
មាសប្រាក់ស្រូវអង្ករ　　ទុកឲ្យល្អកុំសប្បុរស
សំចៃកុំឲ្យអស់　　មើលថៃថ្នូនខ្លួនឯងណា ។
ស្ងួវស្ងួចកុំឲ្យដាច់　　បើវាតិចឲ្យឧស្សាហ៍
រិះរកផ្សំទៀតណា　　ឲ្យបានច្រើនក្រវើនទុក ។
នឹងចាយឲ្យគិតក្រោយ　　ទោះនឹងឲ្យៗមើលមុខ
កុំឲ្យសុកគ្រលុក　　ទោះនឹងទុកឲ្យចំណារ ។
ជិតដល់ធ្វើចំការ　　ឲ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ
ស្លឹកគ្រៃខ្ទីត្រប់ត្រុំ　　ត្រាវត្រសក់សព្វបន្លែ ។
៣៥. កុំខ្ជិលកុំច្រអូស　　ទៅងងួតរត់សុំគេ
គេមិនឲ្យឯងទេ　　តែគឺមោះព្រោះខ្ជិលទុក ។
ទោះធ្វើស្រែចំការ　　ឲ្យឧស្សាហ៍មើលថៃទាំ
កុំខ្ជិលកុំប្រចាំ　　ចបចូកជីកស្មៅវល្លិផង ។
កុំឲ្យបង់កម្លាំង　　ទោះខែប្រាំងប្រើឲ្យដង
ទឹកទៅស្រោចស្រប់ផង　　ឲ្យលូតលាស់មានផ្លែផ្កា ។
ធ្វើការកុំគិតព្រួយ　　ខ្លួនឯងមួយកុំត្អូញត្អែរ

# ច្បាប់ប្រុស

ខ្លាំងខ្សោយកុំអោយល្វែ ខ្លាចតែនឿយហើយមិនធ្វើ ។
ជាងយប់បិតឫស្សី ត្បាញជាល្អីតៅកញ្ជើ
កុំអោយស្រីស្តីលើ ឥតអំពើធ្វើលេងទៅ ។
៤០. កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ
ខាងផ្ទះខាងលំនៅ អោយវាលកាលកើតសុខា ។
អោយមានក្តីបារម្ភ ធ្វើស្រែកុំចោលចំការ
ដឹងដែកកាំបិតព្រា ទុកអោយជាកុំអោយបាត់ ។
ដេកយប់អោយរាំងទ្វា ទ្រព្យជាៗប្រុងប្រយ័ត្ន
ត្រចៀកចាំកុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន ។
ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថៃថូន
ទោះទ្រព្យរបស់ខ្លួន អោយសួរកូនសួរប្រពន្ធ ។
កុំអាងឯងជាប្រុស បាត់របស់មិនគិតគន់
មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា ។
៤៥. ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ
ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត ។
អោយប្រាប់អ្នកនៅផ្ទះ កុំរលះឥតគំនិត
គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា ។
បើទៅជាមានភ័ព្វ ប្រសើរគាប់នោះឥតថា
ប្រសិនពានពស់ខ្លា ខ្យល់ចាប់ចុកឥតគេសម ។
ទោះដើរមានដំណឹង អោយរំពឹងគិតបារម្ភ
នឹងដើរៗអោយសម យប់ព្រលប់អោយមាត់ក ។
កុំស្ញៀមកុំស្វាត់ពួន លបលាក់ខ្លួនខ្លាចមិនល្អ
អោយមើលអោយមាត់ក ដើរអោយស្មោះសោះគេថា ។
៥០. ទោះខ្លួនជាប៉ុន្មាន ពាក្យសណ្តានវែងមុសា
គេម៉ៃមកអាត្មា តាមដំណឹងដំណើរខុស ។

# ច្បាប់ប្រុស

កូនអើយបាកុំផ្លោយ　　កុំធ្លាក់អោយអាប់កេរ្តិ៍យស
ធម្មតាកើតជាប្រុស　　អោយរករៀនច្បាប់មាត្រា ។
លោកហៅថាឆ្កួតបី　　មួយឆ្កួតស្រីមួយឆ្កួតស្រា
មួយឆ្កួតល្បែងពាលា　　លេងបៀរបោរធួកំតាត់ ។
ទាក់មាន់ទាក់ទទា　　ជល់ភ្នាល់គ្នាបរបាញ់សត្វ
អន្ទាក់ដាក់បង្កាត់　　ល្បែងអស់នោះឥតកំណើត ។
ធម្មតាប៉ោនិងបៀរ　　មិនដែលខ្មែរណានិងកើត
មិនឮមានកំណើត　　មានតែលិចលង់ខ្លួនទេ ។
៥៥. ជួនកាលគេចាញ់ឯង　　រៀងរាល់ល្បែងតែងតែរេ
មានកាលគេចាញ់គេ　　កុំទុកចិត្តថាឯងប៉ិន ។
ពីព្រឹកស្លៀកហូលជរ　　ល្ងាចស្លៀកសខ្វះចងក្បិន
ពីព្រឹកត្បកក្បាលចិន　　ល្ងាចមិនទាន់ចិនដាក់ខ្នោះ ។
ជួនកាលវាចងជើង　　ព្យួរខ្ពស់ឡើងក្បាលដាំចុះ
ភ្នែកស្លឹងតឹងក្រញុះ　　វាទារប្រាក់អោយបានឆាប់ ។
មើលមុខល្អតិចអ្វី　　មិនខ្មាសស្រីផ្សារឈរស្តាប់
មុខមិញដូចគេស្លាប់　　មាត់ស្ញេញស្ញាញពេបដូចក្មេង ។
ស្រែកថ្ងូរអេះអូយអើយ　　អាចិកអើយអាណិតលែង
អញរកប្រាក់ឲ្យឯង　　អោយអាចិកស្អែកនេះបាន ។
៦០. ចិនឮព្រមស្រាយមក　　បណ្តើររកប្រាក់សណ្តាន
តឹងទារទាល់តែបាន　　ទ្រព្យអោយទៅទើបវាលែង ។
អ្នកអាយអ្នកអើយកុំ　　គួរបារម្ភរាល់តែល្បែង
កុំលកុំលួបលេង　　គួរអោយរៀងអោយរៀរចុះ ។
កុំឈរកុំឈប់ជិត　　ក្រែងមិនអត់បង់កេរ្តិ៍កោះ
កុំល្បងល្បែងនោះសោះ　　គួរអោយដោះអោយដើរចេញ ។
ច្បាប់នេះចាំរាល់ខ្លួន　　ទោះបងប្អូនមិត្តសំឡាញ់

ពឹងខ្លួនឯងអោយចេញ ធានាទ្រព្យគេយកទៅ ។
ឯទ្រព្យបានទៅវា ឯងធានាស្រាប់តែនៅ
វាបានទ្រព្យយកទៅ ខ្លួនឯងនៅធានាស្រាប់ ។
៦៥. ដល់គេមកតឹងទារ អ្នកធានាក៏បានឆាប់
មិនបានគេប្រចាប់ ទៅជាខ្ញុំព្រោះធានា ។
ទោះបងប្អូនធុរៈ ក្រជំ(ចំ)ពាក់គេតឹងទារ
បើមានទ្រព្យជួយគ្នា កុំធានាណាអ្នកអាយ ។
កូនអើយគួរបាចាំ ឪពុកផ្តាំកុំបីណាយ
ប្រយ័ត្នរាល់រូបកាយ កុំអោយភ្លេចពាក្យនេះណា ។
មួយទៀតហៅឆ្កួតស្រី គួរកុំបីសេពកាមា
វាតែងទាញអាត្មា នាំវង្វេងភ្លេចបាបបុណ្យ ។
ភ្លេចសីលទានសូន្យសោះ ភ្លេចឃ្មាងឃ្មោះដល់ជីពជន្ម
ភ្លេចទោសភ្លេចទាំងគុណ ភ្លេចទាំងការកាន់រសាយ ។
៧០. បង្កើតតែទោសទុក្ខ បើបានសុខសឹងប្រែក្លាយ
បង្កើតក្តៅក្រហាយ អោយទាស់ទែងខឹងនិងគ្នា ។
ចងទោសគុំគង្គួន មិនគិតខ្លួនខ្លាចមរណា
មានកាលក្ស័យនិងមា គុំធ្វើគ្នាអោយសោះសូន្យ ។
បង្កើតតែចិត្តធំ ចៅគុំនុំនិងជីដូន
ឯបងខឹងនិងប្អូន ម្តាយនឹងកូនគុំធ្វើគ្នា ។
រីឯខ្ញុំគាប់ម្ចាស់ អោយក្តៅណាស់ក្នុងអង្គា
កើតទោសខឹងនឹងគ្នា ជាគុំនុំពុំគ្រាស្បើយ ។
មានកាលគេដាក់ឃ្នាង វាមិនរាងចាលចិត្តឡើយ
លក់ព្ទៃខ្ញុំគេហើយ មិនខ្លាចស្លាប់ដល់អាត្មា ។
៧៥. គេកាប់ដោតទាំងក្បាល មិនចេះចាលចិត្តឡើយណា
ភ្លេចខ្លួនសូន្យសោះសា នឹងតែគ្រប់សេពសប្បាយ ។

រីឯកាមកិលេស កុំប្រហែសគួរអោយណាយ
ស្និតណាស់ណាអ្នកអាយ អ្នកអើយកុំគិតសង្ស័យ ។
នេះឯងហៅឆ្កួតស្រី គួរកុំបីអោយអាល័យ
ចូរចេងចាំសព្វថ្ងៃ ទុកទូន្មានគ្រប់អាត្មា ។
អ្នកប្រាជ្ញលោកនិទាន ទុកទូន្មានរាល់រូបា
មួយហៅឆ្កួតសុរា នោះកុំផឹកវាស្រវឹង ។
វានាំភ្លេចវិញ្ញាណ ភ្លេចសីលទានសោះសូន្យឈឹង
ផឹកហើយមិនដែលនឹង នាំចិត្តនោះឲ្យធំក្រៃ ។
៨០. ឯខ្លួនឯងតូចទេ មើលទៅគេប៉ុនមេដៃ
កម្លាំងឯងស្មើថៃ មិនកោតគេតិចឡើយណា ។
ក្អេងក្អាងពាក្យដូចក្អែក អួតប្រកែកបទបានស្រា
មិនខ្លាចរឹទ្ធិនរណា ស្រដីកោងរកកលឈ្លោះ ។
បញ្ចោរបញ្ចៀសផ្ដាស ជេររវាងវាសមិនចំឈ្មោះ
នាំហេតុតែខាងឈ្លោះ ឆ្លើយឆ្លងពាក្យឲ្យបានទាក់ ។
ប្រពន្ធឃើញឃាត់ទៅ ប្ដីមិនត្រូវថាកុំអ្នក
ឯងខឹងលោវាយផាក់ ដោយចិត្តធំបទបានស្រា ។
មានកាលជូនស្រវឹង ពុំបានដឹងខ្លួនឡើយណា
ដើរដួលដេកផ្កាប់ផ្ងារ ស្រាតសំពត់អស់មិនដឹង ។
៨៥. គេឃើញអស់ខ្មាសខ្ញុំ ក្មេងជៀវជុំសើចទ្រហឹង
ដេកដូចគេស្លាប់ឈឹង ក្អែក្អួតពាសពេញទាំងខ្លួន ។
កំណើតអ្នកផឹកស្រា កុំអួតថាឯងនឹងនួន
ដឹងហើយស្រវឹងមួន ខ្លួនខ្សត់ទេអួតថាមាន ។
អ្នកស្លូតទៅជាកាច ឯអ្នកខ្លាចទៅជាហ៊ាន
ខុសត្រូវទៅបំពាន បំពុលខ្លួនឲ្យបានបាប ។
នេះឯងហៅឆ្កួតស្រា ក្នុងធម៌ថាពៀរដរាប

## ច្បាប់ប្រុស

អ្នកណាផឹកហើយបាប	បង់កិត្តិយសពុំសួស្តី ។
គួរកុំសេពសុរា	នាំអាត្មាឲ្យអប្រិយ
នឹងធ្លាក់ទៅអវីចី	នរករងទុក្ខវេទនា ។
៩០. ហៃអស់ជនទាំងឡាយ	កុំវាយមាយក្នុងអង្គា
ចូរស្តាប់ច្បាប់នេះណា	ទុកទូន្មានខ្លួនសព្វថ្ងៃ ។
នេះឯងហៅឆ្លូតបី	លោកស្រដីក្នុងធម៌ថ្លៃ
បើអ្នកណាមួយនៃ	នឹកប្រាថ្នាដោយចំណង់ ។
លោកចងជាឧបមា	ឲ្យអ្នកណាមួយផ្ចិតផ្ចង់
យកដែកដុលបោះបង់	ក្នុងភ្លើងក្រានឆេះច្រាលឆ្អៅ ។
បើកាន់ដែកដែលដុត	នោះមិនមុតមិនមានក្តៅ
កាន់បាននោះទើបហៅ	ចិត្តមុតមែនពិតគិតប្រាណ ។
នោះទើបលោកឲ្យធ្វើ	នូវអំពើទាំងបីបាន
ដោយធម៌ពីបុរាណ	លោកឧបមាដូច្នេះណា ។
៩៥. ចាត់ចែងតែងជាបទ	ព្រហ្មប្រាកដកាលបិតា
ប្រដៅខ្ញុំនេះណា	សព្វសេចក្តីដូច្នេះនៃ ។
កិច្ចការវាយរៀបពោះ	ខ្ញុំមានឈ្មោះបណ្ឌិតមៃ
គិតចងជាសេចក្តី	ប្រដៅជនចប់ម្ល៉េះហោង ។

យើងខ្ញុំជាកូន ខ្ចៅ សំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅ សុខផល ខ្ចៅ វិសាល ខ្ចៅរ៉ាមុន ខ្ចៅ ភារាដា ខ្ចៅ ច់រើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook បង្កើតឡើងដោយ មូលនិធិខ្មែរសំរាប់ការសិក្សា

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្ចៅ ពាញ** នឹង ឧបាសិការ **ឈរ យឿន**

( ឃុំ កំពង់ឃ្លាំង ស្រុក ជីក្រែង ខែត្រ សៀមរាប )

បានវាយបញ្ចូលជា ebook ដោយ ហ៊ត គឹមសេង

កញ្ញា ២០១២

ច្បាប់ប្រុស